ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កក្កដា ២០០៥ / July 2005

កញ្ញា អ៊ូច ចន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី១ ២00៥ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ក្នុងវិស័យកាត់ដេរកើនដល់ ៤៥លានដុល្លារ (១២,៧លានដុល្លារនៅត្រីមាសមុន) ក្នុងនេះគំរោងវិនិយោគថ្មីមាន ២៦,២លានដុល្លារ ដែលមកពី ចិន កម្ពុជា កូរ៉េខាងត្បូង និង US (១១,២លានដុល្លារនៅត្រីមាសមុន) ហើយ ១៨,៨ លានដុល្លារ គឺជាការពង្រីកគំរោងមានស្រាប់ ។ ធៀបនឹង ត្រីមាសទី៤ ២00៤ វិនិយោគអនុម័តក្នុងវិស័យកាត់ដេរថយចុះ ១0% ។

Garment sector fixed asset investments approved by the CDC rose to $45 million in first quarter 2005, from $12.7 million in the preceding quarter. New approvals accounted for $26.2 million in the first quarter, coming from China, Cambodia, South Korea and the United States, compared to $11.2 million in the preceding quarter. The remaining $18.8 million was expansion project approvals, up from $1.5 million. Compared to first quarter 2004, fixed asset investment approvals in the garment sector declined by 10 percent.

**Fixed Asset Investments Approved by CDC for Garment Sector**
(US$ million)




*Note: Data include expansion project approvals.*
Source: Council for the Development of Cambodia

ចំនួនភ្ញៀវបរទេសមកដល់តាមជើងហោះហើរអន្តរជាតិ ថយចុះរហូតតាំងពីដើមឆ្នាំ ២00៥ ចុះដល់ ៦៥.២១២នាក់នៅខែមេសា (៧២.00១ នៅខែមីនា) ប៉ុន្តែធៀបនឹង ខែមេសា ឆ្នាំមុន វាឡើង ៤៣% ក្នុងនេះភ្ញៀវចូលតាមអាកាសយានដ្ឋានសៀមរាបកើន ៦១% ដល់ ៣១.៧៣0នាក់ និងតាមអាកាសយានដ្ឋានភ្នំពេញកើន ២៩% ដល់ ៣៣.៤៨២នាក់ ។

Monthly arrivals of foreign visitors using international flights have continued to drop since the beginning of 2005, amounting to 65,212 persons in April, down from 72,001 persons in March. This downward trend will continue in May if the pattern for a number of previous years is repeated. Compared to April one year earlier, however, the total number of foreign visitor arrivals by air rose by 43 percent. Arrivals at Siem Reap international airport increased by 61 percent to 31,730 persons, while arrivals at Phnom Penh international airport rose by 29 percent to 33,482 persons.

**Foreign Visitor Arrivals by International Flights**
(thousand persons)




*Note: Latest data available are for April 2005.*
Source: Ministry of Tourism

នៅខែមេសា ២00៥ គំរោងសាងសង់បានអនុម័តនៅភ្នំពេញ ចុះដល់ ៧,៨ លានដុល្លារ ក្រោយមានកំនើនយ៉ាងខ្លាំងនៅខែមីនា ដល់ ៦៤លានដុល្លារ (២២,៤លានដុល្លារ នៅខែមេសា ២00៤) ។ តំលៃនៃ គំរោងសាងសង់ភូមិគ្រឹះ/ផ្ទះ និងផ្ទះល្វែង ថយចុះពី ៥លានដុល្លារ ដល់ 0,៦លានដុល្លារ និងពី ១៧លានដុល្លារ ដល់ ៥,៨លានដុល្លារ រៀងគ្នា ចំណែកឯ សំណង់ផ្សេងទៀតកើនពី 0,៤លានដុល្លារ ដល់ ១,៣លានដុល្លារ ។

The value of construction project approvals in Phnom Penh declined to $7.8 million in April, after a sharp increase in March, when it reached $64 million. The corresponding figure for April 2004 was $22.4 million. The value of villa and house and flat construction decreased from $5 million to $0.6 million and from $17 million to $5.8 million, respectively. Other construction rose from $0.4 million to $1.3 million.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for April 2005.*
Source: Department of Cadastre and Geography, municipality of PP

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែមិថុនា ថ្លៃសាំងនៅភ្នំពេញឡើងចុះក្នុងចន្លោះពី ៣.២០០-៣.៣៥០ រៀល/លីត្រ ហើយថ្លៃម៉ាស៊ូតឡើងចុះពី ២.៤០០-២.៦០០រៀល/លីត្រ ។ ថ្លៃជាមធ្យមគឺ ៣.២៤១រៀល/លីត្រ សំរាប់សាំង និង ២.៤៨៧,៥រៀល/លីត្រ សំរាប់ម៉ាស៊ូត គឺកើនពី ៣.២៣៥រៀល/លីត្រ និង ២.៤៧៥រៀល/លីត្រ នៅខែឧសភា រៀងគ្នា ។ ថ្លៃអង្ករលេខ២ នៅភ្នំពេញគ្មានការប្រែប្រួល គឺនៅត្រឹម ១.០៥០រៀល/គ.ក នៅខែឧសភា និង មិថុនា ។

During June, the price of gasoline in Phnom Penh fluctuated between 3,200 riels/litre and 3,350 riels/litre, while the price of diesel fluctuated between 2,400 and 2,600 riels/litre. The average price of gasoline and diesel was 3,241 riels/litre and 2,487.5 riels/litre in June, rising from 3,235 riels and 2,475 riels, respectively, in May. The price of second quality rice in Phnom Penh remained unchanged at 1,050 riels/kg between May and June.

### Prices of Gasoline, Diesel Oil and Second Quality Rice in Phnom Penh




Sources: CDRI and National Institute of Statistics

នៅខែឧសភា ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបន្តកើនឡើង ប៉ុន្តែយឺតៗជាងកាលពីខែមុន។ ថ្លៃទំនិញទូទៅកើន ០,៦%នៅខែឧសភា ធៀបនឹង ១,៣% នៅខែមេសា ។ កំណើនយឺតជាងមុននេះ បណ្តាលជាសំខាន់មកពីការថយកំណើនថ្លៃម្ហូបអាហារ, ការនៅនឹងថ្លៃសាំង និងម៉ាស៊ូត, និង ការចុះថ្លៃសំលៀកបំពាក់ និងស្បែកជើង ។

Consumer prices in Phnom Penh continued to rise in May, although more slowly than in the preceding month. Overall prices rose by 0.6 percent in May, compared to 1.3 percent in April. The slower increase mainly resulted from a slowing of food price rises, stable gasoline and diesel prices and declining clothing and footwear prices.

### Consumer Price Index

(July–December 2000=100)




*Note: Latest data available are for May 2005.*
Source: National Institute of Statistics

ថ្លៃមាសនៅភ្នំពេញបន្តកើនយ៉ាងខ្លាំងដល់ ៥២,៦ដុល្លារ/ជី នៅត្រីមាសទី១ ២០០៥ ដែលជាកំរិតខ្ពស់បំផុតតាំងពីឆ្នាំ១៩៩៩ មក ។ មាសបានឡើងថ្លៃ ១២% ពីកំរិត ៤៧ដុល្លារ/ជី នៅត្រីមាសមុន និង ១៤%ពីកំរិត ៤៦ដុល្លារ/ជីនៅត្រីមាសទី១ ២០០៤ ។

Gold prices in Phnom Penh continued to rise sharply, reaching $52.6 per *chi* in the first quarter 2005, the highest level since 1999. It rose by 12 percent from $47 per *chi* in the preceding quarter and 14 percent from $46 per *chi* in the first quarter 2004.

### Gold Price in Phnom Penh

(US$ per *chi*)




Source: CDRI and MEF

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rate and Monetary Developments

នៅខែមិថុនា ២០០៥ ប្រាក់រៀលប្តូរបាន ៤.១១៤រៀល/ដុល្លារ គឺវាបន្តចុះថ្លៃទល់នឹងដុល្លារUS បើធៀបនឹងខែឧសភា ដែលមានអត្រាប្តូរ ៤.០៨០រៀល/ដុល្លារ ។ នៅខែមិថុនាឆ្នាំមុន ប្រាក់រៀលមានអត្រាប្តូរ ៤.០៣១រៀល/ដុល្លារ ។

In June 2005, the riel traded at 4,114 riels/dollar, continuing to depreciate against the US dollar as compared to May, when it traded at 4,080 riels/dollar. During the same month last year, the riel exchange rate with the US dollar was 4,031 riels/dollar.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែមិថុនា ២០០៥ ប្រាក់រៀលឡើងថ្លៃ ២% ទល់នឹងប្រាក់បាតថៃ ដល់ ១០១,២រៀល/បាត។ ធៀបនឹងប្រាក់ដុងវៀតណាម ប្រាក់រៀលបន្តចុះថ្លៃដល់ ២៥,៧រៀល/១០០ដុង នៅខែមិថុនា ធៀបនឹង ២៥,៤រៀល/១០០ដុង នៅខែឧសភា ។

The riel appreciated against the Thai baht in June, by 2 percent to 101.2 riels/baht. Against the Vietnamese dong, the riel continued to fall, reaching 25.7 riels per 100 dong in June from 25.4 in May.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI and the *Economist*

រូបិយវត្ថុទូទៅបន្តកើនឡើងដល់ ៤.៥៨៦,៧ពាន់លានរៀល នៅខែមេសា ២០០៥ រឺ កំណើន ២% ធៀបនឹងត្រីមាសមុន ។ ក្នុងនេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ២% ដល់ ៨០៧,៨លានដុល្លារ (៣.២៦៨,២ពាន់លានរៀល) គឺលឿនជាងកំណើនក្នុងខែមុន ។ ប្រាក់រៀល ទាំងនៅក្នុង និងនៅក្រៅធនាគារ បន្តកើនឡើង (ថ្វីបើយឺតៗជាងកាលពីខែមុនក្តី) បាន ០,៨% ដល់ ១.៣១៨,៥ពាន់លានរៀល ។

Liquidity continued to rise, reaching 4,586.7 billion riels in April 2005—a rise of 2 percent from the preceding month. Foreign currency deposits increased by 2 percent, to $807.8 million (3,268.2 billion riels), faster than the increase in the preceding month. Riels both inside and outside banks continued to increase, although more slowly than in the previous month.

**Liquidity of the Banking System**
(billion riels)




*Note: Data revised for March 2005.*
*Latest data available are for April 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

ការនាំចេញសរុបរបស់កម្ពុជាឡើងដល់ ១៥១លានដុល្លារ នៅខែមេសា រឺ ១១,៣% ច្រើនជាងនៅខែមីនា។ ដោយឡែកការនាំចេញផលិតផលកាត់ដេរ កើន ១៤,៦% ដល់ ១៤៧,៤លានដុល្លារក្នុងរយ:ពេលនេះ ។ ក្នុងរយ:ពេលដដែល ការនាំចេញផលិតផលកសិកម្មចំបង១ ជាអាទិ៍ កៅស៊ូ អង្ករ និង ត្រី ថយចុះ ៤៧% ដល់ ១,៥លានដុល្លារ ក្នុងនេះ ការនាំចេញ កៅស៊ូ ថយចុះ ៦១% ដល់ 0,៩លានដុល្លារ, រីឯការនាំចេញ អង្ករ និងត្រី កើន ៤0% ដល់ 0,៣លានដុល្លារ និង ៤% ដល់ 0,៣លានដុល្លារ រៀងគ្នា ។

Cambodia's total exports amounted to $151 million in April, 11.3 percent more than in March. Exports of garment products rose by 14.6 percent to $147.4 million during this period. At the same time, exports of main agricultural products, including rubber, rice and fish, declined by 47 percent to $1.5 million. Rubber exports dropped by 61 percent to $0.9 million, while rice and fish rose by 40 percent to $0.3 million and by 4 percent to $0.3 million, respectively.

## Cambodia's Main Exports
(US$ million)




*Note: Latest data available are for April 2005.*
Source: Customs and Excise Department

ការនាំចូលបារី មានចំនួន ២៤,២លានដុល្លារនៅខែមេសា រឺ ថយចុះ ២៨% ធៀបនឹងខែមីនា ។ ក្នុងពេលជាមួយគ្នា ការនាំចូលស៊ីម៉ង់ត៍ និងដែក ក៏ថយចុះដែរអស់ ៧% ដល់ ១៣លានដុល្លារ និង ២0% ដល់ ៦លានដុល្លារ ។ ធៀបនឹងកាលពីមួយឆ្នាំមុន ការនាំចូលបារី និងស៊ីម៉ង់ត៍ កើន ៣% និង ៤% ចំណែកឯការនាំចូលដែកថយចុះ ៣២% ។

Imports of cigarettes amounted to $24.2 million in April, a decrease of 28 percent from March. Imports of cement and steel also declined during this period, by 7 percent to $13 million and by 20 percent to $6 million, respectively. Compared to a year earlier, imports of cigarettes and cement climbed by 3 percent and 4 percent, whereas steel imports declined by 32 percent.

## Imports of Cigarette and Construction Materials
(billion riels)




*Note: Latest data available are for April 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

នៅខែមេសា ម៉ាស៊ូត និងសាំងនាំចូល មានតំលៃសរុប ៤៧,២លានដុល្លារ រឺ ២៨,៦%ច្រើនជាងនៅខែមីនា ។ ការនាំចូលម៉ាស៊ូតកើនតំលៃយ៉ាងខ្លាំងបាន ៥៥,៧% ដល់ ៣៦,៦លានដុល្លារ ចំណែកឯការនាំចូលសាំងថយចុះ ១៩,៧% ដល់ ១0,៦លានដុល្លារ ។ ធៀបនឹងខែមេសា ២00៤ ការនាំចូលម៉ាស៊ូតថយចុះ ១៧,៤% ពីកំរិត ៤៤,៣លានដុល្លារ ឯការនាំចូលសាំងថយចុះ ២,៧% ពីកំរិត ១0,៩លានដុល្លារ ។

The value of diesel and gasoline imports totalled $47.2 million in April, 28.6 percent more than in March. The value of diesel imports rose by 55.7 percent to $36.6 million, while gasoline imports decreased by 19.7 percent to $10.6 million. Compared to April 2004, diesel imports decreased by 17.4 percent from $44.3 million, and gasoline imports declined by 2.7 percent from $10.9 million.

## Imports of Petroleum Products
(billion riels)




*Note: Latest data available are for April 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅឆ្នាំ២០០៥ ថវិកាសិលា ៩,៣លានដុល្លារ បានគ្រោងសំរាប់វិនិយោគតាមខេត្ត និងបែងចែកទៅឱ្យ ៤វិស័យអភិវឌ្ឍន៏ចំបង១ គឺ សេដ្ឋកិច្ច, សង្គមកិច្ច/យេនឌ័រ, ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន (NREM)/land និងផែនការ/ពតិមាន ។ វិនិយោគតាមខេត្តខាងអភិវឌ្ឍន៏សេដ្ឋកិច្ច មានចំនែកធំបំផុតគឺ ៥,៤លានដុល្លារនៅឆ្នាំ២០០៥ ធៀបនឹង ៦,៨លាននៅ ២០០៤។

In 2005, a SEILA budget of $9.3 million is planned for provincial investment, allocated to four major development sectors: economic, social/gender, natural resources and environment management (NREM)/land and planning/information. Provincial investment in economic development accounts for the largest share—$5.4 million in 2005, down from $6.8 million in 2004, followed by social/gender ($2.8 million up from $2.47 million). The planned budget for NREM/land amounts to $0.7 million, down from $1.56 million, while planning/ information receives $0.3 million, up from $0.27 million.

**SEILA 2005 Budget for Provincial Investment, by Main Development Sectors**
(US$ million)




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ថវិកាសិលា ឆ្នាំ២០០៥ សំរាប់វិនិយោគតាមខេត្តខាងអភិវឌ្ឍន៏សេដ្ឋកិច្ច ដែលមានសរុប ៥,៤លានដុល្លារ ត្រូវបានបែងចែកឱ្យ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម (៣,៥៧លានដុល្លារ ទល់នឹង ២,៩៣លាន នៅឆ្នាំ២០០៤), ផ្លូវជនបទ (០,២៧លាន ទល់នឹង ១,៤លាន), សាធារណការ (០,០៨លាន ទល់នឹង ០,០៦លាន), ទេសចរណ៍ (០,០២លាន ទល់នឹង ០,០១លាន) និង រ៉ែ/ឧស្សាហកម្ម (០,០១លាន និងជា មុខចំនាយថ្មីនៅ ឆ្នាំ២០០៥) ។

The 2005 SEILA budget for provincial investment in economic development, which totals $5.4 million, is broken down into agricultural extension ($3.57 million, up from $2.93 million in 2004), water resources ($1.5 million, from $2.4 million), rural roads ($0.27 million, from $1.4 million), public works ($0.08 million, from $0.06 million), tourism ($0.02 million, from $0.01 million) and mines/industry ($0.01 million, a new item in 2005).

**SEILA 2005 Budget for Provincial Economic Investment**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ថវិកាសិលាសំរាប់វិនិយោគតាមខេត្តខាងអភិវឌ្ឍន៏សង្គមកិច្ច/យេនឌ័រ មានសរុប ២,៨លានដុល្លារនៅឆ្នាំ២០០៥ ធៀបនឹង ២,៥លាននៅឆ្នាំ២០០៤ និងផ្តោតជាសំខាន់លើ ទឹកស្អាត/អនាម័យ(០,៩លានដុល្លារ), យេនឌ័រ (០,៨លាន), អប់រំ (០,៥លាន), អភិវឌ្ឍន៏សហគមន៏ (០,៣លាន), សុខភាព (០,២លាន), វប្បធម៌ និងសាសនា (០,០៥លាន), និង សង្គមកិច្ច (០,០៥លាន) ។

A total of $2.8 million of SEILA funds is devoted to provincial investment in social/gender development in 2005, compared to $2.5 million in 2004. Social/gender development focuses primarily on rural water/sanitation ($0.9 million, from $0.8 million), gender ($0.8 million, from $0.6 million), education (stable at around $0.5 million), community development ($0.3 million, from $0.2 million), health ($0.2 million, from $0.3 million), culture and religion (about $0.05 million in both years) and social affairs ($0.05 million, from $0.04 million).

**SEILA 2005 Budget for Provincial Investment in Social/Gender Development**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកុម្ភៈ ២០០៥ អតិរេកថវិកាចរន្តថយចុះដល់ ៩៨,៤ពាន់លានរៀល ពីកំរិត ១៦៩,៣ពាន់លានរៀលនៅខែមុន ។ ការថយចុះអតិរេកនេះឆ្លុះបញ្ចាំងពីកំណើនយ៉ាងខ្លាំងក្នុងចំណាយចរន្ត (ពី ៩,៣ ដល់ ៨២,២ពាន់លានរៀល) រីឯចំណូលចរន្តសឹងតែគ្មានការប្រែប្រួល (កើនពី ១៧៨,៦ ដល់ ១៨០,៦ពាន់លានរៀល) ។ ប៉ុន្តែអតិរេកចរន្តនេះ មានកំរិត ២៧% ខ្ពស់ជាងកាលពីខែកុម្ភៈ ២០០៥ ។

In February 2005, the current budget surplus declined to 98.4 billion riels, from 169.3 billion riels in the preceding month. The decrease in surplus reflected a sharp increase in current expenditure (from 9.3 to 82.2 billion riels), while current revenue remained almost unchanged (from 178.6 to 180.6 billion riels). The current surplus was 27 percent higher than in February 2004.

**Current Budget Operations**
(billion riels)




*Note: Provisional for Jan–Dec 2004 and Jan–Feb 2005.*
Source: Ministry of Economy and Finance

នៅខែកុម្ភៈ ២០០៥ ចំណូលថវិកាចរន្តមានចំនួន ១៨០,៦ពាន់លានរៀល រឺកើន ២ពាន់លានរៀល លើសពីខែមុន(១៧៨,៦ពាន់លានរៀល) ។ ក្នុងនេះពន្ធក្នុងស្រុកកើន ៤,៥% ដល់ ១០៥,៥ពាន់លានរៀល គឺបានប៉ះប៉ូវដល់ការថយចុះចំណូលពន្ធគយ (ចុះ ៦% ដល់ ៣៣,៥ពាន់លានរៀល) និងចំណូលមិនមែនពន្ធ (ចុះ ០,៨% ដល់ ៤១,៦ពាន់លានរៀល) ។ ចំណូលចរន្តនេះកើន ២៤% បើធៀបនឹងខែកុម្ភៈ ២០០៤ (១៤៦ពាន់លានរៀល) ។

In February, current revenue was 180.6 billion riels, up 2 billion riels from 178.6 billion riels in the previous month. Domestic tax increased by 4.5 percent to 105.5 billion riels, offsetting the decline in customs duties and non-tax revenues (by 6 percent to 33.5 billion riels and by 0.8 percent to 41.6 billion riels, respectively). Current revenue rose by 24 percent from 146 billion in February 2004.

**Current Budget Revenue**
(billion riels)




*Note: Provisional for Jan–Dec 2004 and Jan–Feb 2005.*
Source: Ministry of Economy and Finance

នៅខែកុម្ភៈ ២០០៥ ចំណាយថវិកាចរន្តកើនដល់ ៨២,២ពាន់លានរៀល រឺកើនប្រហែល ៧៣ពាន់លានរៀល លើសពីខែមុន (៩,៣ពាន់លានរៀល) ។ ក្នុងនេះ មានចំណាយសរុប ២២,៣ពាន់លានរៀល សំរាប់ខាងការពារជាតិ និងសន្តិសុខ, ១៨ពាន់លានរៀល ខាងសង្គមកិច្ច, ១៦,២ពាន់លានរៀល ខាងរដ្ឋបាលទូទៅ, និង ២ពាន់លានរៀលខាងរដ្ឋបាលសេដ្ឋកិច្ច ។ ធៀបនឹងខែដូចគ្នាឆ្នាំ២០០៤ ចំណាយចរន្តកើន ២០% ។

In February, current expenditure amounted 82.2 billion, up about 73 billion riels from 9.3 billion riels in the preceding month. In February, a total of 22.3 billion riels went into defence and security, 18 billion riels to social administration, 16.2 billion riels to general administration, 2 billion riels to economic administration and the rest to other expenditure. Compared to the same month of 2004, current expenditure was 20 percent higher.

**Current Budget Expenditure**
(billion riels)




*Note: Provisional for Jan–Dec 2004 and Jan–Feb 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅឆ្នាំ២០០៤ US មានឱនភាពលើពាណិជ្ជកម្មទំនិញនិងសេវា ខ្ពស់បំផុត ដល់ ៦១៧,៥៨ពាន់លានដុល្លារ គឺត្រូវជា ២៤%ខ្ពស់ជាងឆ្នាំមុន និង ៣៦% ខ្ពស់ជាងមធ្យមភាគ៥ឆ្នាំ ២០០០-២០០៤ ។ នៅឆ្នាំ២០០៤ EU និងជប៉ុន កើនអតិរេកលើទំនិញនិងសេវា ដល់ ១៧៨ពាន់លានដុល្លារ និង ៩៤ពាន់លានដុល្លារ រៀងគ្នា (កើន ២៦% និង ៣០% ខ្ពស់ជាងឆ្នាំ២០០៣) ។

In 2004, the United States deficit on trade in goods and services was the greatest ever at $617.58 billion. This is about 24 percent higher than in the previous year and 36 percent higher than the five-year average 2000–2004. In 2004, the EU and Japan increased their trade surpluses from the previous year. The surplus on goods and services in the EU was recorded at $178 billion, 26 percent higher than the previous year. The surplus on goods and services in Japan was $94 billion, about 30 percent higher than in 2003.

**Balance on Goods and Services in the US, EU and Japan** (US$ billion)




Sources: BEA, Eurostat and Bank of Japan

នៅឆ្នាំ២០០៤ អតិរេកលើពាណិជ្ជកម្មទំនិញនិងសេវា នៅកូរ៉េខាងត្បូង កើនដល់ ២៩,៣៩ពាន់លានដុល្លារ ធៀបនឹង ១៤,៥៥ពាន់លានដុល្លារនៅឆ្នាំ២០០៣ ឯនៅ ហុងកុង វាកើនដល់ ១៦,៤ពាន់លានដុល្លារ រឺ ១៥% ខ្ពស់ជាងឆ្នាំ២០០៣ ។

In 2004, the surpluses on goods and services in Hong Kong and South Korea increased over the previous year. South Korea’s trade surplus was $29.39 billion, compared to $14.55 billion in 2003. Hong Kong’s trade surplus was $16.4 billion, 15 percent higher than in 2003.

**Balance on Goods and Services in China, Hong Kong and South Korea** (US$ billion)




*Note: 2004 data for China are not yet available.*
Sources: Bank of Korea and Hong Kong Department of Statistics

នៅឆ្នាំ២០០៤ អតិរេកលើពាណិជ្ជកម្មទំនិញនិងសេវា នៅសិង្ហបុរី និង ម៉ាឡេស៊ី កើនឡើង ឯនៅថៃ វាធ្លាក់ចុះ ។ នៅឆ្នាំ២០០៤ អតិរេកពាណិជ្ជកម្មសិង្ហបុរី កើនយ៉ាងខ្លាំងដល់ ៥៣,៥៨ពាន់លានដុល្លារ (៣០,៤៥ពាន់លានដុល្លារនៅឆ្នាំ២០០៣), នៅម៉ាឡេស៊ី វាកើនយឺតជាងដល់ត្រឹម ២៥,១៨ពាន់លានដុល្លារ, ឯនៅថៃ វាថយចុះបន្តិចដល់ត្រឹម ៧,០៨ពាន់លានដុល្លារ (៨,៨ពាន់លានដុល្លារនៅឆ្នាំ២០០៣) ។

In 2004, the surpluses on goods and services in Singapore and Malaysia increased, while in Thailand it fell. Singapore’s trade surplus recorded a dramatic increase to $53.58 billion in 2004 from $30.45 billion in 2003. Malaysia’s surplus rose relatively slowly to $25.18 billion in 2004. The surplus on goods and services of Thailand in 2004 declined slightly to $7.08 billion from $8.8 billion in 2003.

**Balance on Goods and Services in Selected ASEAN Countries** (US$ billion)




Sources: Countries’ national statistic offices and national banks

# ស្ថានភាពអតិផរណានៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

នៅខែមេសា អ្នកប្រើប្រាស់នៅជប៉ុនបានថយចុះអារម្មណ៍ទុទិដ្ឋិ ដោយសារគេប្រមើលឃើញនូវការកែលំអក្នុងបៀវត្សរ៍ និងការងារ ។ ថ្លៃទំនិញប្រើប្រាស់កើនបន្តិចធ្វើឱ្យបំរែបំរួលសរុបក្នុង ១២ខែ មានកំរិត 0% ។ នៅខែមេសា ថ្លៃទំនិញប្រើប្រាស់ នៅ EU មានអត្រាកំនើនប្រចាំឆ្នាំគ្មានការប្រែប្រួលអស់៤ខែហើយនៅត្រឹម ២,១% ឯនៅ US វាកើនដល់ ៣,៥% ។

Japan's consumers were less pessimistic in April as the outlook for wages and employment improved. Consumer prices rose slightly, taking the cumulative change for 12 months to 0 percent. Japan's central bank governor has vowed to maintain the bank's zero interest rate policy until prices stop falling. During April, consumer price increases remained unchanged at an annualised rate of 2.1 percent for the fourth consecutive month in the EU and rose to 3.5 percent in the US.

### Inflation Rates in the US, Europe and Japan

(percentage change over the previous year)




*Note: The latest data available are for April 2005.*
Sources: IMF and the *Economist* (18–24 June 2005)

នៅខែមេសា អត្រាអតិរណាទំនិញប្រើប្រាស់នៅចិន ថយចុះមកត្រឹម ១,៨% ពីកំរិត ២,៧%នៅខែមីនា ដោយសារជាសំខាន់ការធ្លាក់ថ្លៃម្ហូបអាហារ ហើយនៅហុងកុង វាមានកំរិត 0,៥%ខ្ពស់ជាងកាលពីមួយឆ្នាំមុន (ទាបជាងកំរិត 0,៨%សំរាប់ខែមីនា) ដោយសារកំណើនតិចក្នុងថ្លៃកញ្ចប់ខ្សែទស្សនកិច្ច គ្រឿងអលង្ការ និងអាហារជាមូលដ្ឋាន ។ នៅកូរ៉េខាងត្បូង ថ្លៃទំនិញប្រើប្រាស់ កើន ៣,១%ក្នុងរយៈមួយឆ្នាំដល់ចុងខែមេសា ។

China's annual consumer inflation rate eased to 1.8 percent in April, down from 2.7 percent in March, driven to a large extent by a drop in food prices. Hong Kong consumer prices in April were 0.5 percent higher than a year earlier, a smaller increase than the 0.8 percent rise in the year to March, due to moderated increases in the prices of package tours, jewellery and basic foodstuffs. In South Korea, consumer prices increased by 3.1 percent in the year through April.

### Inflation Rates in China, Hong Kong and South Korea (percentage change over the previous year)




*Note: The latest data available are for April 2005.*
Sources: IMF and the *Economist* (18–24 June 2005)

នៅសិង្ហបុរី ថ្លៃទំនិញប្រើប្រាស់កើន 0,៤%ក្នុងរយៈមួយឆ្នាំដល់ចុងខែមេសា ដែលឆ្លុះបញ្ចាំងពីថ្លៃអាហារ និងការអប់រំ ហើយធនាគារកណ្ដាលបានទុកឱ្យដុល្លារសិង្ហបុរីឡើងថ្លៃ ដើម្បីទប់កំណើនអតិផរណា ។ ក្នុងពេលដដែល ថ្លៃទំនិញប្រើប្រាស់នៅថៃ កើន ៣,៦% គឺលឿនជាង កំរិត ៣,២% សំរាប់ខែមីនា ឯអត្រាអតិផរណាគិតក្នុងមួយឆ្នាំនៅម៉ាឡេស៊ី មានកំរិត ២,៧% ធៀបនឹង ២,៦%សំរាប់ខែមីនា ។

Consumer prices in Singapore increased 0.4 percent in the year through April, reflecting higher food and education costs. The central bank has been allowing the Singaporean dollar to strengthen to help keep inflation in check. During the same period, Thailand's consumer price index rose 3.6 percent year on year, accelerating from 3.2 percent a month earlier. Malaysia's inflation in April was an annualised 2.7 percent, up from 2.6 percent in the year to March.

### Inflation Rates in Selected ASEAN Countries

(percentage change over the previous year)




*Note: The latest data available are for April 2005.*
Sources: IMF and the *Economist* (18–24 June 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rate in the World Markets

នៅខែមិថុនា ដុល្លារUS ឡើងថ្លៃទល់នឹងរូបិយវត្ថុចំបងៗ គឺ ១ដុល្លារប្តូរបាន ០,៨២អឺរ៉ូ (០,៧៩អឺរ៉ូ នៅខែឧសភា) រឺ ១០៨,៤៤យ៉េន (១០៦,៦៥យ៉េន នៅខែឧសភា) ។ កត្តាធំៗក្នុងរឿងនេះគឺ ឱនភាពពាណិជ្ជកម្មUSតូចជាងការរពឹងទុក, ការរំពឹងពីកំនើនអត្រាការប្រាក់US, ការរំពឹងពីការថយកំនើនសេដ្ឋកិច្ច និងការថយចុះអត្រាការប្រាក់នៅ EU, និងការបារម្ភពីរឿងប្រេងឡើងថ្លៃ និងការថយចុះអតិរេកពាណិជ្ជកម្មជប៉ុន ។

In June 2005, the US dollar gained its value against most major currencies. It was traded at 0.82 against the Euro, up from 0.79 a month earlier. Against the Japanese yen, it was exchanged at 108.44 from 106.65 in May. The main factors behind these developments are less-than-expected US trade deficit and expectations of higher interest rates in the United States, speculation about slower economic growth and lower interest rates in the EU, and concerns about surging oil prices and a shrinking trade surplus in Japan.

**Euro and Japanese Yen Against the US Dollar**




*Note: Data are up to 27 June 2005*
Sources: The Federal Reserve Bank of New York

នៅខែមិថុនា ដុល្លារហុងកុងកើនថ្លៃបន្តិច ដល់ ៧,៧៧ដុល្លារហុងកុង/ដុល្លារ ក្រោយពេលអាជ្ញាធរហុងកុង អនុញ្ញាតឱ្យវាឡើងចុះបានពី ៧,៧៥-៧,៨៥ ដុល្លារហុងកុង/ដុល្លារUS ។ ក្នុងពេលដដែល ប្រាក់វ៉ុនកូរ៉េខាងត្បូងប្តូរបាន ១.០០៩,៥៩វ៉ុន/ដុល្លារUS ធៀបនឹង ១.០០១,៧៥វ៉ុន/ដុល្លារUS ខែមុន ។

In June 2005, the Hong Kong dollar strengthened slightly against the U.S dollar after the Hong Kong authorities adopted a wider band of 7.75 to 7.85 HKD per US dollar. The Hong Kong dollar traded at 7.77 HKD/USD, from 7.79 a month earlier. During the same period, the South Korean won fell against the U.S dollar, exchanged at 1009.59 Won/USD from 1001.75 Won/USD in May. The South Korean won was weighed down by potential interest hike in the US and worries over increasing oil prices.

**South Korean Won and Hong Kong Dollar Against the US Dollar**




Note: Data are up to 27 June 2005
Sources: The Federal Reserve Bank of New York

នៅខែមិថុនា ២០០៥ ដុល្លារសិង្ហបុរីចុះថ្លៃទល់នឹង ដុល្លារUS ដោយប្តូរបាន ១,៦៧ដុល្លារសិង្ហបុរី/ដុល្លារUS (១,៦៥១ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែឧសភា) ។ ប្រាក់បាតថៃក៏ធ្លាក់ថ្លៃដល់ ៤០,៨៤បាត/ដុល្លារUS ដែរ គឺចុះអស់ ២,៦%ធៀបនឹងខែមុន ។ ដូចរូបិយវត្ថុអាស៊ីឯទៀតដែរ ការធ្លាក់ថ្លៃខាងលើគឺដោយសារមានរបាយការណ៍ថា ឱនភាពពាណិជ្ជកម្មUS តូចជាងការគិតទុក នឹងការវាយស្មានថា អត្រាការប្រាក់US នឹងកើនឡើងទៀត ។

In June 2005, the Singapore dollar lost its value against the USD, falling to 1.67 SGD/USD from 1.651 SGD/USD in May 2005. During the same period, the Thai baht also eroded against the USD, trading at 40.84 THB/USD, a 2.6 percent depreciation from a month earlier. Along with most other Asian currencies, the Singapore dollar and the Thai bath weakened against the USD, after there was a report that the US trade gap was less than previously forecast and on speculation that the Fed would raise its benchmark interest rate.

**Thai Baht and Singaporean Dollar Against the US Dollar**




*Note: Data are up to 27 June 2005*
Sources: The Federal Reserve Bank of New York

[*] against the Euro

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែឧសភា ថ្លៃអង្ករក្នុងពិភពលោកធ្លាក់ចុះ ដោយសារមានអង្ករច្រើនសំរាប់នាំចេញ ថ្វីបើប្រទេសនាំចូលមានតំរូវការច្រើនដែរក្តី ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) បានថយចុះ ១%ទាបជាងខែមុន ដល់ ១១៩,៤ឯកតា ។ នៅខែឧសភានេះ ថ្លៃអង្ករនៅ US មានលំនឹងត្រឹម ៣០៩ដុល្លារ/តោន ឯនៅថៃ វាថយចុះ ១% ដល់ ២៩៧ដុល្លារ/តោន ពីកំរិត ២៩៩ដុល្លារ/តោន នៅខែមេសា ។ ការចុះថ្លៃអង្ករនៅថៃ បណ្តាលជាសំខាន់ពីនយោបាយទ្រទ្រង់ថ្លៃក្នុងស្រុករបស់រដ្ឋាភិបាល ។ ថ្លៃអង្ករនៅអាស៊ីអាចបន្តធ្លាក់ចុះទៀត ដោយសាររដូវប្រមូលផលលើកទី២ បានមកដល់ហើយ ។

In May, world rice prices fell due to a large amount of rice available for export, even with an active import demand. The international prices index (IPO) decreased by 1 percent from the previous month to 119.4 points. Rice prices in the US in May were stable at $309 per ton. In Thailand, prices decreased by 1 percent to $297 per ton from $299 per ton in April. The decrease in the Thai rice price is mainly due to a government policy of supporting domestic prices. The rice price in Asia may continue falling as the second harvest arrives.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Source: Osiriz/InfoArroz and InterRice.

នៅខែមិថុនា ថ្លៃសណ្តែកសៀង និងពោតកើនឡើង។ សណ្តែកសៀងឡើងថ្លៃ ៨%ខ្ពស់ជាងខែមុន ដល់ ២៦៧,៧៦ដុល្លារ/តោន ហើយពោតឡើងថ្លៃ ៣% ដល់ ៩៨,១៥ដុល្លារ/តោន ។ ថ្លៃប្រេងឆានៅខែឧសភា ធ្លាក់ចុះ ៣%ទាបជាងខែមុន ដល់ ៤១៧ដុល្លារ/តោន រឺ ប្រហែល ១៩%ទាបជាងថ្លៃនៅខែឧសភា ២០០៤ ។

The price of soybeans and maize rose in June. The price of soybeans increased by 8 percent from the previous month to $267.76 per ton, and maize rose by 3 percent to $98.15 per ton. The price of palm oil in May declined by 3 percent from the previous month to $417 per ton, about 19 percent lower than the price in May 2004.

**International Prices of Palm Oil, Soybeans and Maize** (US$/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែមិថុនា ថ្លៃប្រេងឆៅ និងសាំង កើនឡើង ។ ក្នុងនេះថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៤៨,៨៣ដុល្លារ/ធុង រឺ កើន ៩%ខ្ពស់ជាងខែមុន ។ ថ្លៃលក់ដល់ដៃរបស់ OPEC ត្រូវបានកំណត់ ១% ខ្ពស់ជាងថ្លៃលក់ដល់ដៃរបស់គ្រប់ប្រទេស ។ ថ្លៃសាំងធម្មតានៅ US Gulf Coast កើន ៧% ដល់ ៣៩,៩១សេន/លីត្រ ធៀបនឹង ៣៧,១៩សេន/លីត្រ នៅខែមេសា ។

In June, the prices of crude oil and gasoline rose. The OPEC spot price for crude oil was $48.83 per barrel, a 9 percent increase from the previous month. The OPEC spot price is set just 1 percent higher than the all-country spot price. Regular gasoline on the US Gulf Coast rose by 7 percent to 39.91 cents per litre, compared to 37.19 cents per litre in April.

**Prices of Crude Oil and Gasoline**




***Note: Data are up to 26 May** 2005.*
Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ជំនួយច្រើនទៀតសំរាប់ជនក្រីក្រនៅកម្ពុជាៈ** អ្នកដឹកនាំសហភាពអឺរ៉ុប បានផ្ដល់ជំនួយ ៦៥,៩លានដុល្លារដល់កម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៏ខាងសេដ្ឋកិច្ច សង្គមកិច្ច និងអភិបាលកិច្ចល្អ ។ ជំនួយនេះមាន ២ចំនែក ។ ចំនែកទី១ សហភាពអឺរ៉ុប នឹងផ្ដល់ ៣៥,៥លានដុល្លារសំរាប់កិច្ចសហប្រតិបត្តិការផ្តោតលើការអភិវឌ្ឍន៏សេដ្ឋកិច្ច ការទ្រទ្រង់ខាងសង្គមកិច្ច និងអភិបាលកិច្ចល្អ ។ចំនែកទី២ នឹងផ្ដល់ ៣០លានដុល្លារសំរាប់សកម្មភាពអភិវឌ្ឍន៏រយៈពេលវែង សំដៅកាត់បន្ថយភាពក្រីក្រក្នុង ៣ខេត្តខាងពាយព្យ ។ តាំងពីឆ្នាំ១៩៩២មក ជំនួយឥតសំណងរបស់គណៈកម្មការអឺរ៉ុបមកកម្ពុជា មានសរុបជាង ៤៨៥លានដុល្លារ ។

**អគ្គិសនីកម្ពុជាប្រកាសឡើងថ្លៃអគ្គិសនីៈ** អគ្គិសនីកម្ពុជាដែលជាសហគ្រាសរដ្ឋ បានគ្រោងតំលើងថ្លៃអគ្គិសនីនៅក្រុងភ្នំពេញ និងខេត្តកណ្ដាល នៅខែកក្កដា ។ កាលពីមុន អតិថិជនបង់ថ្លៃ ៣៥០៛/kwh សំរាប់ ៥០kwh ដំបូងដែលប្រើអស់, ៥៥០៛/kwh សំរាប់ចន្លោះ ៥០-១០០kwh, និង ៦៥០៛ សំរាប់ចំណែកលើសពី ១០០kwh ។ តាមតំលៃថ្មី ត្រូវបង់ ៥៥០៛ លើគ្រប់ kwh ទាំងអស់ បើសិនប្រើលើសពី ៥០kwh ហើយត្រូវបង់ដល់ ៦៥០៛ លើគ្រប់ kwh បើសិនប្រើលើសពី ១០០ kwh ។ អ្នករស់នៅភ្នំពេញបានត្អូញត្អែរថា ថ្លៃអគ្គិសនីសព្វថ្ងៃវាខ្ពស់ជាងនៅវៀតណាម និងថៃ រួចទៅហើយ ហើយអ្នកជំនាញការខាងអាជីវកម្ម បានក្រើនរំលឹកថា ថ្លៃនេះអាចបង្អាក់ទឹកចិត្តពួកវិនិយោគិន ។

**ក្រុមហ៊ុន CMBV ចុះកិច្ចព្រមព្រៀងទិញសិទ្ធិរុករកមាសពីក្រុមហ៊ុន Oksan Cambodia:** ក្នុងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុន CMBV ទិញយក ៨៥%នៃភាគហ៊ុនលើសិទ្ធិរុករក និងធ្វើអាជីវកម្មលើដី ៨៤គ.ម២ នៅតំបន់អន់ត្រុង ក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី ។ ផ្អែកលើអង្កេតរបស់អ្នកសិក្សាពីដី និងវិស្វករខាងរ៉ែ ក្រុមហ៊ុន Oksan បានប៉ាន់ថា មានរ៉ែផ្ទុកជាតិមាស ប្រមាណ ៦,៣លានតោននៅក្នុងកន្លែងទទួលបានអាជ្ញាប័ណ្ណនេះ ។ ក្នុងរបាយការណ៏របស់ក្រុមហ៊ុន មានចុះបញ្ជាក់ថា អាចមានរ៉ែមាសមានតំលៃប៉ាន់ស្មានសរុបដល់ទៅ ១,៨ពាន់លានដុល្លារ ។

**ថ្លៃប្រេង បានបង្កើនការបារម្ភពីឱនភាពនៅអាស៊ីៈ** ថ្លៃប្រេងខ្ពស់ បានបង្កើនការបារម្ភពីកំនើនឱនភាពគណនីចរន្តនៅប្រទេសថៃ និង ឥណ្ឌា ហើយមន្ត្រីរបស់កូរ៉េខាងត្បូង បានទស្សន៏ទាយពីការថយកំណើនសេដ្ឋកិច្ចក្នុងឆ្នាំនេះ ។ រដ្ឋមន្ត្រីហិរញ្ញវត្ថុកូរ៉េខាងត្បូង Han Duck-soo បាននិយាយថា កំណើនសេដ្ឋកិច្ចប្រហែលធ្លាក់ចុះពីកំរិតរំពឹងទុក ៥% មកត្រឹម ៤% ដោយសារថ្លៃប្រេងខ្ពស់បានប៉ះពាល់ដល់តំរូវការក្នុងស្រុក និងការនាំចេញ ។ ពួកមន្ត្រីក្នុងប្រទេសមិនសូវអភិវឌ្ឍន៏ មានការបារម្ភកាន់តែខ្លាំងពីកំណើនឱនភាពគណនីចរន្ត និងកំណើនអតិផរណា ។

**More aid for Cambodia's poor:** The European Union executive has extended aid worth $65.9 million to Cambodia to boost economic and social development as well as good governance. The executive signed a two-part deal with the Cambodian government. Under the first arrangement, the EU will make available $35.5 million for cooperation focused on economic development, social sector support and good governance. The second arrangement will provide $30 million for long-term development activities aimed at alleviating poverty in three northwestern provinces. Grant aid from the European Commission to Cambodia since 1992 totals more than $485 million. (Cited from ABC Radio Australia, 21 June 2005)

**EdC Announces Hike in Electricity Costs**: State-run Electricité du Cambodge is planning to increase the cost of electricity in Phnom Penh and Kandal province by July. Previously, customers were charged 350 riels/kwh for the first 50 kwh used, 550 riels/kwh for 50–100 kwh and 650 riels for more than 100 kwh. With the new billing system, customers who pass the first 50 kwh threshold will pay the higher cost of 550 riels for every kwh used to that point, those who break the 100 kwh threshold will pay 650 riels for every kwh used to that point. Residents of Phnom Penh have long complained that electricity costs are already higher than in Vietnam and Thailand, and business experts warn that the costs deter investors. (Cited from the Cambodia Daily, 11–12 June 2005)

**CMBV Signs Agreement to Acquire Significant Gold Exploration Interests from Oksan Cambodia:** Cambodian Ventures Limited (CMBV) has signed a definitive agreement to acquire gold exploration interests from Oksan Cambodia Corporation. CMBV has acquired an 85 percent controlling interest in an 84 square kilometre mineral exploration and exploitation licence in an area called Antrong, in Kaev Seima district, Mondolkiri province. Based on surveys by geologists and mining engineers, Oksan estimates that about 6.3 million tons of gold-bearing mineral ore exist within the licensed area. As stated in their report, the total potential value of gold deposits in the licensed area is estimated at about $1.8 billion. (Cited from press.arrivenet.com, 9 June 2005)

**Oil price heightens Asian deficit fears:** The high price of oil has heightened concerns about widening current account deficits in Thailand and India, with South Korean officials predicting a slowdown in economic growth this year. Han Duck-soo, South Korea's finance minister, said economic growth was likely to drop from an expected 5 percent to about 4 percent, reflecting the impact of high oil prices on domestic demand and exports. Officials in less developed countries have become increasingly concerned about their widening current account deficits and a possible rise in inflation. (Cited from Financial Times, 27 June 2005)